**សុន្ទរកថា**

**របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ថ្លែងបើកសន្និបាតបូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ ២០១០**

**និង លើកទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ ២០១១**

**រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១១**

- *ឯកឧត្តមបណ្ឌិត* ***ចម ប្រសិទ្ធ*** *ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម*
- *ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី*
- *សមាជិក សមាជិកាទាំងអស់ នៃអង្គសន្និបាតជាទីមេត្រី !*

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមជាអធិបតីក្នុងពិធីបើកអង្គសន្និបាតប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម ដែលបានរៀបចំឡើង ដើម្បីបូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ ២០១០ និង លើកទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ ២០១១ តាមការអញ្ជើញសារជាថ្មីម្តងទៀតរបស់ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ ជាមួយនេះដែរ ខ្ញុំសូមធ្វើគារវកិច្ចយ៉ាងកក់ក្តៅបំផុត ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងពាណិជ្ជកម្មទាំងអស់ ជាពិសេសចំពោះអស់លោក លោកស្រី ជាទីប្រឹក្សាពាណិជ្ជកម្មអមស្ថានឯកអគ្គរាជទូតកម្ពុជានៅបរទេស និង មកពីគ្រប់បណ្តាខេត្តនានា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតដ៏សំខាន់នេះ ។

សន្និបាតរបស់ក្រសួងពាណិជ្ជកម្មនាឆ្នាំ ២០១១ នេះ គឺជាការបូកសរុបនូវលទ្ធផលការងារឆ្នាំទី ៣ នៃការអនុវត្ត យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា របស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំសូមឆ្លៀតយកឱកាសនេះ សំដែងនូវការកោតសរសើរ ដោយស្មោះ ចំពោះក្រសួងពាណិជ្ជកម្ម ដែលបានរៀបចំសន្និបាតបូកសរុបការងារពាណិជ្ជកម្មប្រចាំឆ្នាំនេះឡើង និង សូមវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និង មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្មទាំងអស់ ដែលបានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយ និងប្រាជ្ញាស្មារតី ក្នុងបុព្វហេតុរួមជំរុញវិស័យពាណិជ្ជកម្ម ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ហើយទទួលបាននូវលទ្ធផលគួរជាទីមោទនៈ ក្នុងរយៈពេលពេញមួយឆ្នាំ ២០១០ កន្លងទៅ ។ ជាពិសេស ខ្ញុំសូម កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលបានគ្រប់គ្រង និងដឹកនាំការងារក្នុងវិស័យនេះប្រកបដោយ ជវភាព ប្រសិទ្ធភាព និងឧត្តមភាព ព្រមទាំងសម្រេចបានលទ្ធផលជាផ្លែផ្កាជាច្រើន ជូនប្រទេសជាតិជាបន្តបន្ទាប់ឥតដាច់ ពីមួយឆ្នាំទៅមួយឆ្នាំ ។

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី !

បន្ទាប់ពីសម្រេចបានជោគជ័យធំៗជាច្រើន ជាពិសេសការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់រយៈពេលមួយទសវត្សរ៍ ព្រមទាំងការធ្លាក់ចុះនៃអត្រាភាពក្រីក្រគួរឱ្យកត់សម្គាល់ សេដ្ឋកិច្ចកម្ពុជាត្រូវទទួលរងនូវផលប៉ះពាល់ពីវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក នៅចុងឆ្នាំ ២០០៨ ដែលបានជះឥទ្ធិពលខ្លាំងដល់វិស័យសេដ្ឋកិច្ចរួបវន្ត ទន្ទឹមនឹងការប្រឈមក្នុងកិច្ចការពារអធិបតេយ្យភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលបានដឹកនាំសេដ្ឋកិច្ចកម្ពុជាឆ្លងផុតពីដំណាក់កាលដ៏លំបាកបំផុតពីវិបត្តិសេដ្ឋកិច្ច ទន្ទឹមនឹងការធានារក្សាបានទាំងស្រុងនូវអធិបតេយ្យភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយគន្លឹះជាកញ្ចប់ប្រទាក់ក្រឡាជាច្រើន ដើម្បីទប់ទល់ និងសម្រាលនូវបច្ច័យអាក្រក់ដែលបណ្តាលមកពីវិបត្តិនេះ ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានគោលនយោបាយដ៏សមស្រប និងបានផ្តល់នូវការឆ្លើយតបយ៉ាងទាន់ពេលវេលា ដើម្បីស្រោចស្រង់ និងលើកស្ទួយវិស័យ ដែលទទួលរងផលប៉ះពាល់ខ្លាំងជាងគេ រួមមាន វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងទីផ្សារអចលនទ្រព្យ ។ ផ្អែកលើសមិទ្ធិផលទាំងនេះ បានធ្វើអោយកម្ពុជាសម្រេចបានយ៉ាងលឿននូវការកាត់បន្ថយភាពក្រីក្រ ។ អត្រានៃ

ប្រជាជនកម្ពុជាដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្របានថយចុះពី ៣០,៧% នៅឆ្នាំ ២០០៧ មក នៅត្រឹម ២៧,៤% នៅឆ្នាំ ២០០៩ ហើយត្រូវបានគណនាថា បានធ្លាក់ចុះទៀត មកនៅត្រឹម ២៥,៨% នៅឆ្នាំ ២០១០ ។ កម្ពុជាត្រូវបានអង្គការសហប្រជាជាតិចាត់ទុកថា ស្ថិតនៅក្នុងចំណោមប្រទេសឆ្នើមចំនួន ៥ នៅក្នុងពិភពលោកដែលទទួលបាននូវសមិទ្ធិផលយ៉ាងខ្លាំងក្លាឆ្ពោះ ទៅសម្រេចបាននូវគោលដៅសហសវត្សរ៍នៅក្នុងឆ្នាំ ២០១៥ ។

កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០១០ បានចាប់ផ្តើមងើបឡើងវិញតាមទម្រង់ជាអក្សរវេ (V) ដែលអាចនឹងសម្រេចបានប្រមាណជាង ៥% អាស្រ័យដោយការកើនឡើងវិញនៃការនាំចេញសម្លៀកបំពាក់ ភ្ញៀវទេសចរណ៍បរទេស និងកំណើនវិស័យកសិកម្ម បន្ទាប់ពីបានធ្លាក់ចុះក្នុងកម្រិត ០,១% នៅក្នុងឆ្នាំ ២០០៩ កន្លងទៅនេះ ដោយសារទទួលរងផលប៉ះពាល់ពីវិបត្តិកលិយុតហិរញ្ញវត្ថុអន្តរជាតិ ពីការធ្លាក់ចុះសេដ្ឋកិច្ច ពីព្យុះកេតសាណា និង ពីការប្រឈមក្នុងកាតព្វកិច្ចការពារអធិបតេយ្យភាព និង បូរណភាពទឹកដី ក្នុងឆ្នាំ ២០០៨ និង ឆ្នាំ ២០០៩ មក ។ ក្នុងឆ្នាំ ២០១០ នេះ អត្រាអតិផរណាឆ្នាំលើឆ្នាំ ស្ថិតក្នុងកម្រិត ៣% ហើយអត្រាជាមធ្យមប្រចាំឆ្នាំ ៤% ។ អត្រាប្តូរប្រាក់រៀល- ដុល្លារអាមេរិក ស្ថិតក្នុងរង្វង់ ៤០៥០ រៀល ក្នុង ១ ដុល្លារអាមេរិក ហើយទុនបម្រុងធានាបានការនាំចូលយ៉ាងតិចប្រមាណ ៣ ខែ ជាប្រចាំ ។ កំណើនសេដ្ឋកិច្ចកម្ពុជា នៅក្នុងឆ្នាំ ២០១១ នេះ អាចនឹងសម្រេចបាន ៦% ហើយអតិផរណានឹងរក្សាអោយស្ថិតក្នុងរង្វង់ ៤,៥% ដោយរាជរដ្ឋាភិបាលត្រូវអនុវត្ត គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង គោលនយោបាយរូបិយវត្ថុសមស្រប និង ប្រុងប្រយ័ត្ន ។ រាជរដ្ឋាភិបាលរក្សាអប្បមាទខ្ពស់ចំពោះបាតុភូតដែលអាចនាំឱ្យមានការរាលដាលអតិផរណាលើឆាកអន្តរជាតិ មកលើកម្ពុជា ដោយការឡើងថ្លៃប្រេងឥន្ធនៈ ស្បៀងអាហារ និង វត្ថុធាតុដើម ។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី !**

ខ្ញុំមានជំនឿយ៉ាងមុតមាំថា សន្និបាតនាពេលនេះ គឺជាឱកាសមួយដ៏ល្អ សម្រាប់យើងទាំងអស់គ្នា ជាពិសេសទាំងមន្ត្រីដែលកំពុងបំពេញការងារជាទីប្រឹក្សាអមទូតកម្ពុជានៅឯបរទេស និងទាំងមន្ត្រីនៅថ្នាក់មូលដ្ឋាន បានមកជួបជុំគ្នា ធ្វើការពិចារណាបូកសរុបលទ្ធផល ដើម្បីរួមគ្នាពិភាក្សា និង ផ្លាស់ប្តូរយោបល់ និង បទពិសោធន៍ ក្នុងឆ្នាំ ២០១០ កន្លងទៅ និង រិះរកវិធានការអភិវឌ្ឍន៍

វិស័យពាណិជ្ជកម្ម ។ ជាមួយគ្នានេះ យើងអាចបង្កើនការត្រួតពិនិត្យមើលឡើងវិញនូវបណ្តាសមិទ្ធផលនានាដែលសម្រេចបាន បណ្តាចំណុចខ្វះខាត និកាស និង បញ្ហាប្រឈមផ្សេងៗចំពោះមុខ ព្រមទាំងខិតខំរួមគ្នាស្វែងរកនូវវិធានការណ៍ថ្មីៗ ល្អៗ សំដៅបង្កើតបរិយាកាសពាណិជ្ជកម្មឱ្យកាន់តែល្អប្រសើរ ដើម្បីបន្តជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកម្ពុជា ព្រមទាំងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ស្ថិតក្នុងបរិការណ៍មួយ ដែលសេដ្ឋកិច្ចពិភពលោកកំពុងចាប់ផ្តើមងើបឡើងវិញ ខ្ញុំយល់ឃើញថា ក្រសួងពាណិជ្ជកម្ម គប្បីដើរតួនាទីកាន់តែសកម្មថែមទៀត ជាពិសេសត្រូវជំនះឱ្យបាននូវបញ្ហាប្រឈមនានា ទាំងក្នុងវិស័យពាណិជ្ជកម្មជាតិនិងអន្តរជាតិ ដើម្បីប្រែក្លាយបញ្ហាប្រឈមមុខទាំងនោះ ទៅជានិកាសមាស សម្រាប់រួមចំណែកជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ ។ ក្នុងន័យនេះ ខ្ញុំសូមស្នើអង្គសន្និបាតសូមមេត្តាយកចិត្តទុកដាក់ពិភាក្សារកឱ្យឃើញបញ្ហាគន្លឹះទាំងឡាយ ក្នុងការលើកកម្ពស់ពាណិជ្ជកម្មជាតិ និង អន្តរជាតិ រួចដាក់ទិសដៅគោលនយោបាយ ដោះស្រាយបញ្ហាប្រឈមមុខទាំងនោះ នៅក្រោមក្របខ័ណ្ឌនៃ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ។ ខ្ញុំសូមលើកយកបញ្ហាមួយចំនួនដូចខាងក្រោម ដែលតម្រូវឱ្យមានការគិតគូរឱ្យបានម៉ត់ចត់ :

ទី ១- ការប្រើប្រាស់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងពង្រីកទីផ្សារសម្រាប់ផលិតផលកម្ពុជា

កម្ពុជាបានទទួលនូវការអនុគ្រោះពន្ធនាំចូលលើផលិតផលជាច្រើនមុខ ពីបណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដូចជាៈ សហរដ្ឋអាមេរិក សហភាពអឺរ៉ុប កាណាដា ជប៉ុន អូស្ត្រាលី ចិន កូរ៉េ ជាដើម ។ល។ ជាមួយនេះ កម្ពុជាមានទីផ្សារអនុគ្រោះពន្ធនាំចូល ដែលទទួលបានពីកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន និងជាមួយដៃគូរបស់អាស៊ានដទៃទៀត ក៏ដូចជាទីផ្សារអនុគ្រោះពន្ធនាំចូល ដែលទទួលបានក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោកផងដែរ ។ ដូចនេះ ការខិតខំចាប់យកនិកាសទីផ្សារទាំងនោះ ឱ្យបានជាអតិបរមា គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ សំរាប់ការជំរុញពាណិជ្ជកម្ម និងសេដ្ឋកិច្ចកម្ពុជា និងការកាត់បន្ថយភាពក្រីក្រ។

ទន្ទឹមនឹងនេះ ការខិតខំបន្តពង្រីកនិកាសទីផ្សារ សំរាប់ផលិតផលកម្ពុជា គឺជាកិច្ចការមួយដ៏សំខាន់របស់វិស័យពាណិជ្ជកម្ម ដែលកម្ពុជាត្រូវធ្វើជាប្រចាំ ដើម្បីធានាបាននូវភាពប្រកួតប្រជែងរបស់ខ្លួន ទាំងនៅក្នុងក្របខ័ណ្ឌតំបន់ និង ពិភពលោក ។

**ទី ២ ការជំរុញការនាំចេញអង្ករ**

ក្រសួងពាណិជ្ជកម្ម គឺជាស្ថាប័នដ៏សំខាន់មួយ ក្នុងចំណោមបណ្តាក្រសួង- ស្ថាប័ននានា ដែលមានមុខងារ និង ភារកិច្ច ត្រូវចូលរួមអនុវត្តនូវឯកសារគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលគណៈរដ្ឋមន្ត្រីបានផ្តល់ការអនុម័តកាលពី ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ និងត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០ កន្លងទៅ ។ ក្នុងន័យនេះ ខ្ញុំសូមស្នើក្រសួងពាណិជ្ជកម្ម បន្តចូលរួមអនុវត្តឯកសារគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ តាមការបែងចែកមុខងារ និងភារកិច្ច ដោយភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមសម្រេចនូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលចង់ឱ្យកម្ពុជាក្លាយជាជង្រុកស្រូវ និងជាប្រទេសនាំចេញអង្ករសំខាន់មួយលើទីផ្សារពិភពលោក ដែលក្នុងនោះធ្វើយ៉ាងណានៅឆ្នាំ ២០១៥ ប្រទេសកម្ពុជានឹងអាចផលិតស្រូវលើសឱ្យបានច្រើនជាង ៤ លានតោន ក្នុងនោះ បរិមាណអង្ករសម្រាប់នាំចេញត្រូវសម្រេចឱ្យបានយ៉ាងតិច ១ លានតោន និង ធ្វើឱ្យអង្ករកម្ពុជាត្រូវបាន គេទទួលស្គាល់ជាអន្តរជាតិ ។

**ទី ៣- ការរក្សាស្ថេរភាពថ្លៃទំនិញ និងសន្តិសុខស្បៀង**

ការរក្សាស្ថេរភាពថ្លៃទំនិញប្រើប្រាស់ប្រចាំថ្ងៃ ជាពិសេសថ្លៃគ្រឿងឧបភោគបរិភោគ មានសារៈសំខាន់ណាស់ សំរាប់ធានាលំនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងសម្រាប់ស្ថេរភាពសង្គម និងការអភិវឌ្ឍន៍ប្រទេស ។ ក្នុងន័យនេះ ខ្ញុំសូមស្នើក្រសួងពាណិជ្ជកម្ម បន្តធ្វើការតាមដានតំលៃទំនិញសំខាន់ៗនៅលើទីផ្សារ និងមានវិធានការសមស្រប ដើម្បីទប់ស្កាត់ការដំឡើងថ្លៃទំនិញទាំងនោះ ដើម្បីបញ្ចៀសផលវិបាកទាំងឡាយដែលអាចកើតមានឡើងជាយថាហេតុ ។

**ទី៤- ការកសាងបញ្ញត្តិច្បាប់ពាណិជ្ជកម្ម ការរៀបចំ និងការពង្រឹកការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីទប់ស្កាត់ការផលិត ការចែកចាយផលិតផលក្លែងបន្លំ ផលិតផលគ្មានគុណភាព ឬខូចគុណភាព**

ដើម្បីឱ្យយន្តការសេដ្ឋកិច្ចទីផ្សារនៅក្នុងប្រទេសមានដំណើរការកាន់តែប្រសើរឡើង និង ដើម្បីឆ្លើយតបនឹងការវិវត្តន៍ថ្មីៗនៃសភាពការណ៍ពាណិជ្ជកម្មក្នុងតំបន់ និង ពិភពលោក ក្រសួងពាណិជ្ជកម្មចាំបាច់ត្រូវបន្តជំរុញការរៀបចំកសាងច្បាប់ និងបទប្បញ្ញត្តិនានា ដែលនៅខ្វះចន្លោះ

ឱ្យបានសមស្រប ដើម្បីសម្រួល និង ផ្តល់ភាពកក់ក្តៅដល់ធុរៈជន និងវិនិយោគគិន ក្នុងការប្រកបអាជីវកម្មនៅក្នុងប្រទេសយើង ។ ជាមួយនេះ ការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាដែលមានជាធរមាន ក៏ជាការងារចាំបាច់ផងដែរ ។

លើសពីនេះយើងត្រូវបន្តទប់ស្កាត់ផលិតផលក្លែងបន្លំ ផលិតផលគ្មានគុណភាព ឬ ខូចគុណភាព ការប្រកួតប្រជែងមិនស្មោះត្រង់ ដើម្បីការពារសុខមាលភាពរបស់ប្រជាជនយើង និងអ្នកប្រើប្រាស់ជារួម ។ ចំណុចនេះក្រសួងពាណិជ្ជកម្មត្រូវខិតខំលើកកំពស់ឱ្យបានកាន់តែប្រសើរនូវសុវត្ថិភាពម្ហូបអាហារជូនអ្នកប្រើប្រាស់ តាមរយៈវិធានការសមស្រប ដូចជាការផ្តល់ព័ត៌មានស្តីពីភាពគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងឧបភោគបរិភោគ ដែលខូចគុណភាព និងទប់ស្កាត់កុំឱ្យកម្ពុជាក្លាយជាកន្លែងប្រើប្រាស់ផលិតផលមិនល្អទាំងនោះ ។ ទន្ទឹមនេះ ក្រសួងពាណិជ្ជកម្មត្រូវចាត់ចែង និងណែនាំឱ្យទំនិញនាំចូលដែលដាក់លក់នៅទីផ្សារ ត្រូវបិទព័ត៌មានជាភាសាខ្មែរដើម្បីការពារ និងលើកកំពស់សុវត្ថិភាពដល់អ្នកប្រើប្រាស់ និងដើម្បីជៀសវាងនូវគ្រោះថ្នាក់នានាៗ ដែលអាចកើតឡើងជាយថាហេតុ ដោយសារមិនយល់អំពីរបៀបនៃការប្រើប្រាស់ ។

ទី ៥- ការពង្រឹងវិស័យឯកជន ការទាក់ទាញការវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម

ការសម្រួលពាណិជ្ជកម្ម គឺជាកិច្ចការមួយដ៏សំខាន់ ដើម្បីកាត់បន្ថយចំណាយជាពេលវេលា និង ធនធាន ក្នុងការធ្វើអាជីវកម្ម និងបង្កើនភាពប្រកួតប្រជែងរបស់ក្រុមហ៊ុនក្នុងស្រុក ជាមួយនឹងក្រុមហ៊ុនបរទេស ។ ក្នុងន័យនេះ ខ្ញុំសូមស្នើក្រសួងពាណិជ្ជកម្ម បន្តចូលរួម និងបន្តកិច្ចសហការដោយសកម្ម ជាមួយនឹងគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន។ល។ ជាមួយគ្នានេះ ក្រសួងពាណិជ្ជកម្មត្រូវបន្តបង្កលក្ខណៈងាយស្រួលដល់ការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ការចុះបញ្ជីពាណិជ្ជកម្ម និងការចុះបញ្ជីមម៉ាក ដើម្បីគាំទ្រដល់វិស័យឯកជន ជាពិសេសចំពោះសហគ្រាសធុនតូច និងមធ្យម ។

ទី ៦- សមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក

ការបន្តធ្វើសមាហរណកម្មកម្ពុជាចូលទៅក្នុងតំបន់ និងសហគមន៍អន្តរជាតិ នៅតែជាការងារអាទិភាពមួយរបស់រាជរដ្ឋាភិបាល នីតិកាលទី៤ នៃរដ្ឋសភា ។ ក្នុងន័យនេះ ខ្ញុំសូមស្នើក្រសួងពាណិជ្ជកម្ម ដែលជាស្ថាប័ននាំមុខ ត្រូវបន្តយកចិត្តទុកដាក់ក្នុងការបំពេញកាតព្វកិច្ចនៃសមាជិកភាព

របស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក តាមរយៈការរៀបចំអនុម័ត និង ការអនុវត្តច្បាប់ និងបទបញ្ញត្តិទាំងឡាយ និងត្រូវបន្តចូលរួមដោយសកម្មក្នុងការអនុវត្តកម្មវិធីនានា ដែលបាន ព្រមព្រៀងគ្នាកន្លងមក និង កិច្ចសហប្រតិបត្តិការនានា ដែលកំពុងពិភាក្សាទាំងពេលបច្ចុប្បន្ន និង ទាំងពេលអនាគត ។ ក្នុងកិច្ចការនេះ យើងត្រូវបន្តខិតខំទាញយកផលប្រយោជន៍សម្រាប់បើកច្រក ឱ្យផលិតផលកម្ពុជាអាចឈានចូលទីផ្សារ ដោយគ្មានរបាំង និង ឧបសគ្គនានា ទៅកាន់ទីផ្សារ ដ៏ធំធេងក្នុងតំបន់ និង ក្នុងពិភពលោក ដែលនឹងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា ជាកំណើនការវិនិយោគ កំណើនការងារ កំណើនប្រាក់ចំណូល និង កំណើនសេដ្ឋកិច្ចទាំងមូល ។ ជាមួយនេះ យើងត្រូវបន្តប្រឹងប្រែងប្រើប្រាស់ឱ្យអស់សក្តានុពលនូវជំនួយបច្ចេកទេសនានា ដែល ដៃគូអភិវឌ្ឍន៍ផ្តល់ឱ្យ និង ខិតខំស្វែងរកនូវជំនួយបច្ចេកទេសថ្មីៗថែមទៀត ដើម្បីពង្រឹងហេដ្ឋា-រចនាសម្ព័ន្ធ សមត្ថភាព ធនធានមនុស្ស ស្ថាប័នរដ្ឋ វិស័យឯកជន និងសមត្ថភាពផលិត និង ផ្គត់ផ្គង់របស់យើង ។

មុននឹងបញ្ចប់ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នៃក្រសួង- ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល ផ្នែកវិស័យឯកជន និងស្ថាប័នផ្សេងៗទៀត ដែលបានគាំទ្រ និងជួយជំរុញវិស័យពាណិជ្ជកម្មកម្ពុជា ឱ្យមានសន្ទុះរីកចំរើនយ៉ាងឆាប់រហ័ស ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍ ស្រប តាម យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល នីតិកាលទី៤ នៃរដ្ឋសភា ។

ខ្ញុំសូមប្រសិទ្ធពរបវរមហាប្រសើរ ជូនចំពោះ ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង ព្រមទាំងអស់លោក លោកស្រី ជាសមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល សូមប្រកបដោយសុខភាពល្អបរិបូរណ៍ សុភមង្គល និង ទទួលបានជោគជ័យគ្រប់ភារកិច្ច ។

*ខ្ញុំសូមប្រកាសបើកសន្និបាតបូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ ២០១០ និង លើកទិសដៅការងារពាណិជ្ជកម្មឆ្នាំ ២០១១ ចាប់ពីពេលនេះតទៅ ហើយសូមប្រសិទ្ធពរ ជូន អង្គសន្និបាត សូមសម្រេចបានជោគជ័យ ជាអិយ្យេភាព !*